# ថ្នាំវ៉ាក់សាំងជំងឺ Meningococcal Serogroup B (MenB)៖ *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាអេស្ប៉ាញ និងភាសាដទៃទៀត។ សូមចូលទៅwww.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**ជំងឺ** **Meningococcal** គឺជាជំងឺធ្ងន់ធ្ងរ ដែលបង្កឡើងដោយបាគេរីមួយប្រភេទហៅថា*Neisseria meningitidis*។ ជំងឺនេះអាចបណ្តាលឲ្យកើតជំងឺរលាកស្រោមខួរ (ការឆ្លងមេរោគលើស្រោមខួរក្បាល និងឆ្អឹងខ្នង) និងការឆ្លងមេរោគក្នុងឈាម។ ជំងឺ Meningococcal ជាញឹកញាប់ កើតឡើង ដោយគ្មានសញ្ញាព្រមានទេ - សូម្បីតែក្នុងចំណោមមនុស្ស ដែលមានសុខភាពល្អ។

ជំងឺ Meningococcal អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការប៉ះពាល់ជិតគ្នា (ការក្អក ឬថើប) ឬការប៉ះពាល់រយៈពេលយូរ ជាពិសេស ក្នុងចំណោមមនុស្ស ដែលរស់នៅក្នុងផ្ទះតែមួយ។

មានបាគេរី *N. meningitidis* យ៉ាងហោចណាស់ 12 ប្រភេទ ដែលគេហៅថា “serogroups”។ Serogroups A, B, C, W, និង Y បង្កជំងឺ meningococcal ភាគច្រើន។

អ្នកណាក៏ដោយ អាចកើតជំងឺ meningococcal នេះ ប៉ុន្តែ មនុស្សមួយចំនួន មានហានិភ័យកាន់តែខ្ពស់អាចកើតជំងឺនេះ ក្នុងនោះ រួមមាន៖

- កុមារអាយុក្រោមមួយខួប
- ក្មេងជំទង់ និងមនុស្សពេញវ័យ អាយុពី 16 ឆ្នាំ ដល់ 23 ឆ្នាំ
- មនុស្ស មានបញ្ហាសុខភាពមួយចំនួន ដែលប៉ះពាល់ដល់ប្រព័ន្ធស៊ាំ
- អ្នកសិក្សាមីក្រុបជីវសាស្ត្រ ដែលធ្វើការជាមួយនឹងមីក្រុបញែករបស់ *បាក់តេរី N. meningitidis*
- មនុស្ស ដែលស្ថិតក្នុងហានិភ័យ ដោយសារតែមានករណីកើតជំងឺនេះក្នុងសហគមន៍របស់ពួកគេ

សូម្បីតែពេលគេកំពុងព្យាបាលជំងឺនេះ ក៏ជំងឺ meningococcal បានសម្លាប់មនុស្ស 10 ទៅ 15 នាក់ ក្នុងចំណោម 100 នាក់ ដែលកើតជំងឺនេះ។ អ្នកទាំងឡាយ ដែលរស់រានមានជីវិត គឺប្រហែល 10 ទៅ 20 នាក់ ក្នុងចំណោម 100 នាក់ នឹងមានបញ្ហាពិការភាព ដូចជា បាត់បង់ការស្តាប់ ខូចខាតខួរក្បាល ខូចខាតតម្រងនោម កាត់អវៈយវៈ បញ្ហាប្រព័ន្ធប្រសាទ ឬស្លាកស្នាមធ្ងន់ធ្ងរ ដោយសារការរះកាត់ប្តូរស្បែក។

**ថ្នាំវ៉ាក់សាំង Meningococcal Serogroup B (MenB)**អាចជួយបង្ការជំងឺ meningococcal ដែលបង្កឡើងដោយបាគេរី serogroups B។ មានថ្នាំវ៉ាក់សាំង meningococcal ផ្សេង ដើម្បីជួយការពារបាគេរី serogroup A, C, W និង Y។

## 2 ថ្នាំវ៉ាក់សាំងជំងឺ Meningococcal Serogroup B (MenB)៖

ថ្នាំវ៉ាក់សាំង Meningococal Serogroup B ពីរប្រភេទ គឺBexsero® និង Trumenba® Food and Drug Administration (FDA) (បានទទួលអាជ្ញាប័ណ្ណពីរដ្ឋបាលចំណីអាហារ និងឱសថ)។

ថ្នាំវ៉ាក់សាំងទាំងនេះត្រូវបានណែនាំចំពោះមនុស្សអាយុ 10 ឆ្នាំ ឬច្រើនជាងនេះ ដែលមានហានិភ័យកាន់តែខ្ពស់អាចឆ្លងមេរោគ Meningococal បង្កឡើងដោយបាគេរី serogroup B ក្នុងនោះ រួមបញ្ចូល៖

- មនុស្ស ដែលស្ថិតក្នុងហានិភ័យ ដោយសារតែមានករណីកើតជំងឺ meningococcal បង្កឡើងដោយបាគេរី serogroup B។
- ជនណា ដែលខូចខាតលំពែង ឬលំពែងត្រូវបានរះកាត់យកចេញ
- ជនណា ដែលមានបញ្ហាប្រព័ន្ធស៊ាំដ៏កម្រ ដែលគេហៅថា "បញ្ហាខ្វះប្រូតេអ៊ីនខំភ្លីមិន"
- នរណាដែលប្រើប្រាស់ថ្នាំ ហៅថា eculizumab (ហៅផងដែរថា Soliris®)
- អ្នកសិក្សាមីក្រុបជីវសាស្ត្រ ដែលធ្វើការជាមួយនឹងមីក្រុបញែករបស់ *បាក់តេរី N. meningitidis*

ថ្នាំវ៉ាក់សាំងទាំងនេះ ក៏អាចត្រូវបានផ្តល់ឲ្យជនណា ដែលមានអាយុ 16 ឆ្នាំ ដល់ 23 ឆ្នាំ ដើម្បីផ្តល់ការការពាររយៈពេលខ្លីចំពោះប្រភេទភាគច្រើននៃជំងឺ Meningococcal បង្កឡើងដោយបាក់តេរី serogroup B ។ អាយុ 16 ដល់ 18 ឆ្នាំ គឺជាអាយុល្អប្រសើរសម្រាប់ចាក់ថ្នាំវ៉ាក់សាំង។

ដើម្បីទទួលបានការការពារល្អបំផុត គេត្រូវការថ្នាំវ៉ាក់សាំង Meningococcal Serogroup B លើសពី 1ដូស។ ថ្នាំវ៉ាក់សាំងតែមួយត្រូវតែយកមកប្រើសម្រាប់ដូសទាំងអស់។ សូមសួរនាំអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអំពីចំនួនដូស និងពេលវេលាក្នុងការទទួលដូស។

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាក់វ៉ាក់សាំងទាំងនេះទេ។

សូមប្រាប់អ្នកដែលផ្តល់ថ្នាំវ៉ាក់សាំងដល់លោកអ្នក៖

- **ប្រសិនបើលោកអ្នកមានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលគំរាមដល់អាយុជីវិត។**
  ប្រសិនបើលោកអ្នកធ្លាប់មានប្រតិកម្មអាឡាក់ស៊ីដែលគំរាមកំហែងដល់អាយុជីវិត បន្ទាប់ពីបានទទួលដូសមុននៃថ្នាំវ៉ាក់សាំង Meningococcal Serogroup B ឬមានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំងនេះ លោកអ្នកមិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។ *សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលលោកអ្នកដឹង ក្នុងនោះ រាប់ទាំងប្រតិកម្មអាឡាក់ស៊ីទៅនឹងជាតិជ័រកៅស៊ូក្រាស់។* វេជ្ជបណ្ឌិតរបស់លោកអ្នកអាចប្រាប់លោកអ្នកបាន អំពីធាតុផ្សំនៃថ្នាំវ៉ាក់សាំង។
- **ប្រសិនបើអ្នកមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន។**
  ពុំមានព័ត៌មានច្រើន អំពីហានិភ័យ ដែលថ្នាំវ៉ាក់សាំងនេះអាចបង្កឡើងមកលើស្ត្រីមានផ្ទៃពោះ ឬម្តាយបំបៅដោះកូនទេ។ ថ្នាំវ៉ាក់សាំងនេះ គួរត្រូវបានប្រើប្រាស់ ក្នុងអំឡុងពេលមានផ្ទៃពោះតែក្នុងករណីត្រូវការថ្នាំវ៉ាក់សាំងនេះជាក់ច្បាស់ប៉ុណ្ណោះ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

ប្រសិនបើលោកអ្នកមានជំងឺឈឺស្រាល ដូចជា ជំងឺផ្តាសាយ លោកអ្នកប្រហែលអាចទទួលបានថ្នាំវ៉ាក់សាំងនៅថ្ងៃនេះ។ ប្រសិនបើលោកអ្នកមានជំងឺឈឺមធ្យម ឬធ្ងន់ធ្ងរ លោកអ្នកគួរប្រហែលរង់ចាំ រហូតទាល់តែលោកអ្នកជាសះស្បើយវិញ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់យោបល់លោកអ្នក។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះគឺជាផលរំខានស្រាល ហើយអាចបាត់ទៅវិញដោយខ្លួនឯង ក្នុងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្តែ ប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។

មនុស្សលើសពាក់កណ្តាល ដែលទទួលថ្នាំវ៉ាក់សាំង Meningococcal Serogroup B មាន **បញ្ហាកម្រិតស្រាល**បន្ទាប់ពីទទួលថ្នាំវ៉ាក់សាំង។ ប្រតិកម្មទាំងនេះអាចបន្តកើតរហូតដល់ 3 ទៅ 7 ថ្ងៃ ហើយ ប្រតិកម្មទាំងនេះរួមបញ្ចូល៖

- ការឈឺចាប់ ស្នាមក្រហម ឬហើម នៅកន្លែងចាក់ថ្នាំ
- នឿយហត់ ឬអស់កម្លាំង
- ឈឺក្បាល
- ឈឺសាច់ដុំ ឬសន្លាក់
- គ្រុនក្តៅ ឬគ្រុនរងារ
- រោគចង់ក្អួត ឬរោគរាគរូស

**បញ្ហាដទៃទៀតដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងទាំងនេះ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនឈឺស្មារ ដែលអាចកាន់តែធ្ងន់ធ្ងរ និងឈឺយូរជាការឈឺចាប់ធម្មតា បន្ទាប់ពីចាក់ថ្នាំ។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡែកស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡែកស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជា សញ្ញាបង្ហាញពីប្រតិកម្មអាឡែកស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬ ឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពី**ប្រតិកម្មអាឡែកស៊ីធ្ងន់ធ្ងរ** អាចរួមបញ្ចូលកន្ទួរ ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោង ប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជា**ប្រតិកម្មអាឡែកស៊ីធ្ងន់ធ្ងរ** ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនដូច្នោះទេ សូមទូរស័ព្ទទៅគ្លីនិករបស់លោកអ្នក។

  ក្រោយមកគួររាយការណ៍អំពីប្រតិកម្មទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំ)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ**www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក**1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅវិបសាយ VICP តាមអាសយដ្ឋាន **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់ សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  - ចូលទៅវិបសាយ CDC តាមអាសយដ្ឋាន **www.cdc.gov/vaccines**


DCH-3932CA
AUTH: P. H. S., Act 42, Sect. 2126.
Translation provided by the Immunization Action Coalition

Vaccine Information Statement
Serogroup B Meningococcal Vaccine

08/09/2016

Khmer

42 U.S.C. § 300aa-26

Office Use Only

Cambodian

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។